អភិវឌ្ឍន៍កម្ពុជា និង គ្រប់ខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០០

## សេចក្តីសំរេច លេខ ២៩ សសរ

## ស្តីពី

## ការបង្កើត គណៈកម្មការចំរុះ កម្ពុជា-ចាពំង

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

-យោងតាមតំរូវការចាំបាច់របស់រាជរដ្ឋាភិបាល ។

## សំរេច

ប្រការ ១ : បង្កើតគណៈកម្មការចំរុះ កម្ពុជា-ចាពំង ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| -ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| -ឯកឧត្តម ស៊ុយ គឹមអន រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| -ឯកឧត្តម ខុន សំនួន អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| -ឯកឧត្តម ឈៀង យ៉ាណារ៉ា អគ្គលេខាធិការរង នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| -តំណាង ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| -តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| -តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| -តំណាង ក្រសួងពត៌មាន | សមាជិក |
| -តំណាង ក្រសួងសុខាភិបាល | សមាជិក |

-តំណាង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ — សមាជិក

-តំណាង ក្រសួងយុត្តិធម៌ — សមាជិក

-តំណាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ — សមាជិក

-តំណាង អាជ្ញាធរជាតិ APSARA — សមាជិក

-តំណាង សាលាក្រុងភ្នំពេញ — សមាជិក

-ប្រធាន នាយកដ្ឋានអឺរ៉ុប នៃក្រសួងការបរទេស — សមាជិកទទួលបន្ទុកលេខាធិការ

ប្រការ ២ : គណៈកម្មការចំរុះនេះមានបេសកកម្ម :

-ដាក់ចេញនូវទិសដៅធំៗ នៃកិច្ចសហប្រតិបត្តិការនេះ

-ពិនិត្យគុណប្រយោជន៍នៃសកម្មភាពអនុវត្តន៍ទាំងឡាយ ក្នុងកិច្ចសហប្រតិបត្តិការវប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេក ទេស រវាងប្រទេសទាំងពីរ ។

គណៈកម្មការចំរុះនេះ ត្រូវដោះស្រាយរាល់បញ្ហាទាំងឡាយដែលកើតមានក្នុងរយៈពេលកាលនៃសកម្មភាពអនុវត្តន៍ ធ្វើអោយមានការរីកចំរើនដល់កិច្ចសហប្រតិបត្តិការវប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេស ។

ប្រការ ៣ : ដើម្បីបំពេញបេសកកម្មខាងលើ គណៈកម្មការនេះមានភារកិច្ចនិងសិទ្ធិ :

-បង្កើតប្រតិទិនប្រចាំឆ្នាំមួយ សំរាប់អនុវត្តន៍គំរោងផែនការ ដែលភាគីទាំងពីរបានឯកភាព ។

-ធ្វើរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីស្នើសុំគោលការណ៍ ឬ មតិណែនាំ ។

-សមាជិកនៃគណៈកម្មការ ត្រូវចូលរួមប្រជុំការងារ តាមការអញ្ជើញរបស់ប្រធាន ។

-មានសិទ្ធិប្រើត្រា របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការអនុវត្តន៍ភារកិច្ចពាក់ព័ន្ធចាំបាច់ ។

ប្រការ ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួង យុត្តិធម៌ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរជាតិអប្សរា អភិបាលក្រុងភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***